# សេចក្តីរាយការណ៍ពីក្រសួងសាធារណ;សុខាភិបាល
# ស្តីអំពីអ្នកកើតរោគដោយសារមេរោគវេះណែលវ៉ៃរើសមុនគេ

September 7, 2006's DPH Report First Human Case of West Nile Virus

សេចក្តីរាយការណ៍ពីក្រសួងសាធារណៈសុខាភិបាលនៃរដ្ឋម៉ាសាឈូសេត្ស កាលពីថ្ងៃព្រហស្បត្តិ ទី 7 ខែ កញ្ញា ឆ្នាំ 2006 កន្លងមកនេះ បានបញ្ជាក់ឲ្យដឹងថា មានស្ត្រីម្នាក់អាយុ 83 ឆ្នាំនៅក្នុងទីក្រុង Arlington បានត្រូវគ្រូពេទ្យរកឃើញថា ឆ្លងមេរោគវេះណែលវ៉ៃរើស មុនគេបង្អស់ក្នុងរដ្ឋម៉ាសាឈូសេត្សឆ្នាំនេះ។ លទ្ធផលតែស៍នេះ បានបញ្ជាក់ចេញពីមន្ទីរពិសោធន៍នៃក្រសួងសាធាណៈសុខាភិបាល។ អាការៈរោគរបស់អ្នកស្រី បានចាប់ផ្តើមឲ្យដឹង កាលពីថ្ងៃទី 20 ខែ សីហា។ ឥឡូវនេះ គាត់កំពុងសំរាន្តក្នុងមន្ទីរពេទ្យដោយមាន លក្ខណៈធ្ងន់ធ្ងរជាទីបំផុត។ អ្នកស្រីជាអ្នកជម្ងឺម្នាក់ បន្ថែមពលើអ្នកជម្ងឺបីនាក់ទៀត ដែលកើតជម្ងឺ Eastern Equine Encephalitis (EEE) នៅតំបន់ជិត Cap Code រួមទាំងមានម្នាក់ស្លាប់ផង។

នៅឆ្នាំ 2005, ក្នុងរដ្ឋម៉ាសាឈូសេត មានមនុស្សចំនួន 6 នាក់កើតរោគ WNV, រួមទាំងមានម្នាក់ស្លាប់ផង។ នៅឆ្នាំ 2004 និងឆ្នាំ 2005 មានមនុស្សចំនួន 8 នាក់កើតរោគ EEE ដោយមាន 4 នាក់ស្លាប់បាត់បង់ជីវិត។ ការឆ្លងរោគដែលបណ្តាលមកពីសត្វមុស នៅតែមានកើតជាបន្តរបន្ទាប់ទៅទៀត។ ក្រសួងសាធារណៈសុខាភិបាលរាយការណ៍ថា មនុស្សយើងនៅតែអាចឆ្លងរោគ EEE រហូតដល់ធាតុអាកាសចាប់ផ្តើមត្រជាក់ ដែលជាពេលអស់រដូវមុសខាំ។ ឯ រដូវកើតរោគ WNV វិញ គឺមានរហូតដល់ រដូវស្លឹកឈើជ្រុស នៅពេលចាប់ធ្លាក់ទឹកកក។

វេជ្ជបណ្ឌិត Alfred DeMaria ជាអគ្គភ្នាក់ងារពេទ្យនៃក្រសួងសាធារណៈសុខាភិបាល មានប្រសាសន៍ថា ជាការមួយសំខាន់ប្រជាជនគួរចាត់វិធានការណ៍យ៉ាងណា ដើម្បីការពារកាត់បន្ថយ កុំឲ្យមានសត្វមុសខាំ ពីព្រោះរោគទាំងពីរគឺ EEE និងរោគ WNV បានត្រូវរកឃើញថាមានពិតប្រាកដ។

ដើម្បីការពារកុំឲ្យមានមុសខាំ លោកអ្នក គួរ៖

- ចាក់ទឹកដែលមាននៅជុំវិញផ្ទះចោលៈ មុសច្រើនពង់នៅលើទឹកដែលដក ដូច្នេះគួរជៀស វាងកុំឲ្យមានទឹកដក់នៅបរិវេណផ្ទះ។ សូមពិនិត្យមើលទឹកនៅតាមទ, ផើងផ្កា, ឬរបស់ដែលអាចដក់ទឹក ហើយចាក់វាចេញ។
- ពិនិត្យមើលសំណាញ់ទ្វា-បង្អួច កុំឲ្យមានប្រហោងធ្លុះធ្លាយ ពីព្រោះ មូសចូលចិត្តនៅក្នុងផ្ទះជាចាងនៅក្រៅ។

- ជៀសវាងកុំឲ្យមូសខាំ ដោយកុំនៅលេងខាងក្រៅយូរពេក ជាពិសេស នៅពេលមានមូសច្រើន គឺពេលល្ងាចប្រលុបនិងពេលព្រឹកព្រលឹម។ សូមប្រើថ្នាំសំរាប់សម្លាប់មូសនៅលើស្បែកនិងសំលៀកបំពាក់ ទៅតាមវិធីណែនាំលើដប ឬកំប៉ុង។
- សត្វស្លាបស្លាប់អាចជាសញ្ញាឲ្យដឹងថា មានមេរោគ WNV ។ ដូច្នេះ សូមមេត្តារាយការណ៍ អំពីសត្វស្លាបស្លាប់ ទៅក្រសួងសាធារណៈសុខាភិបាលនៃរដ្ឋម៉ាស្សាឈូសេត 1-866-627-7968។ ការធ្វើយ៉ាងដូច្នេះ អាចជួយក្រសួងសុខាភិបាល ឲ្យមានលទ្ធភាពតាមដានមេរោគ WNV នេះឲ្យបានដឹតដល់។

ពត៌មានស្តីអំពីមេរោគ EEE និងមេរោគ WNV  មាននៅក្នុងវិបសៃរបស់ក្រសួងសាធារណៈសុខាភិបាលនៃរដ្ឋម៉ាស្សាឈូសេត ដែលមានអាសយដ្ឋាន www.mass.gov/dph ឬទូរស័ព្ទលេខ 1-866-627-7968។  ចំពោះអស់លោក-លោកស្រីនៅទីក្រុងឡូវែល អស់លោក-លោកស្រីអាចទូរស័ព្ទទៅក្រសួងសុខាភិបាលប្រចាំទីក្រុងឡូវែលលេខ (978) 970-4010។

ពត៌មាននេះដកស្រង់និងបកប្រែចេញពីពត៌មាននៃក្រសួងសាធារណៈសុខាភិបាលនៃរដ្ឋម៉ាស្សាឈូសេត ដោយមណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។